# ការព្រមព្រៀងទៅលើការប្រើប្រាស់អ៊ិនធើនែតឱ្យសមរម្យដោយសិស្សនៅក្នុងក្រសួងអប់រំឡុងប៊ីច

LBUSD Student Acceptable Use Agreement

- គោលបំណងនៃការព្រមព្រៀងទៅលើការប្រើប្រាសសមរម្យដោយសិស្សក្នុងក្រសួងអប់រំឡុងបីចនេះគឺដើម្បីធ្វើឲ្យស្របទៅតាមច្បាប់វិន័យរបស់សហព័ន្ធនិ របស់រដ្ឋ ដូចជាច្បាប់សហព័ន្ធ“ការពារកុមារក្នុងការប្រើប្រាសអ៊ិនធើនែត”(CIPA) ជាដើម ដើម្បីបង្ការពីសកម្មភាពមិនស្របតាមច្បាប់ឬសកម្មភាព ព្យាបាទក្នុងបណ្តាញរបស់ក្រសួងអប់រំឡុងប៊ីច ហើយនិងដើម្បីរក្សាឲ្យជិតនូវពត៏មានសំខាន់ផ្ទាល់ខ្លួនពីការប្រើប្រាសដោយគ្មានការអនុញ្ញាត។
- គោលបំណងនៃការព្រមព្រៀងទៅលើការប្រើប្រាសសមរម្យនេះក៏ដើម្បីបញ្ជាក់ឲ្យប្រាកដថាសិស្សប្រើធនធានបច្ចេកទេសនេះដែលបានផ្តល់ឲ្យដោយក្រសួង អប់រំ ឲ្យស្របទៅតាមបទបញ្ជារបស់ក្រុមប្រឹក្សាភិបាលក្រសួងអប់រំ ដោយក្នុងភាពមានសុវត្ថិភាព មានទំនួលខុសត្រូវដែលគាំទ្រដល់កម្មវិធីបង្ហាត់បង្រៀន ហើយដើម្បីជួយឲ្យលូតលាស់ក្នុងការសិក្សា។
- មុននឹងសិស្សត្រូវបានអនុញ្ញាតឲ្យប្រើធនធានបច្ចេកទេសរបស់ក្រសួងអប់រំ សិស្សនិងមាតាបិតាឬអ្នកអាណាព្យាបាលត្រូវចុះហត្ថលេខាលើក្រដាសព្រម ព្រៀងទៅលើការប្រើប្រាសឲ្យបានសមរម្យនេះដោយមានបញ្ជាក់នូវភារៈកិច្ចនិងទំនួលខុសនានា។

## ការប្រើប្រាសសេវាកម្មអ៊ិនធើនែត

ក្នុងក្រសួងអប់រំឡុងប៊ីច ប្រព័ន្ធអ៊ិនធើនែតទាំងអស់នៅរាល់ទីកន្លែងត្រូវបានតភ្ជាប់តាមប្រព័ន្ធការពារ“បច្ចេកទេស”ដើម្បីតម្រងទប់ព័ត៏មានណាដែលបំពាន លើបទបញ្ជានៃការប្រើប្រាសអ៊ិនធើនែត។ ការតម្រងនេះនឹងទប់ព័ត៏មានភាគច្រើនដែលមិនសមរម្យ ប៉ុន្តែព័ត៏មានដែលមិនសមរម្យខ្លះអាចនៅតែលិចចូល បាន។ សូមប្រាប់ដំណឹងនេះដល់ HelpDesk ដើម្បីឲ្យគេទប់ស្កាត់ព័ត៏មាននេះកុំចូលក្នុងប្រព័ន្ធអ៊ិនធើនែតក្រសួងអប់រំបាន។

## ការរក្សាទុកទិន្នន័យឬបញ្ជីសំណុំរឿង:

បណ្តាញរក្សាទុកសំណុំរឿងត្រូវចាត់ទុកដូចជាទូរដាក់ឥវ៉ាន់របស់សិស្សអញ្ចឹងដែរ ហើយឯក្កភាពនៃការប្រើកុមព្យូទ័ររបស់ក្រសួងអប់រំពុំមានផ្តល់ឲ្យឡើយ។ ព័ត៏មាន សំណុំរឿង និងទំនាក់ទំនងគ្រប់ប្រភេទដែលរក្សាទុកក្នុងកុមព្យូទ័ររបស់ក្រសួងអប់រំគឺជាកម្មសិទ្ធរបស់ក្រសួង ដែលអាចត្រូវឆែកពិនិត្យមើលម្តង កាលនៅក្រោមការបញ្ជារបស់អភិបាលសាលាឬអ្នកតម្រួតឋានៈខ្ពស់ ឬ នាយកដ្ឋានសេវាបច្ចេកទេសនិងពត៏មាន។ ដើម្បីបញ្ជាក់ឲ្យប្រាកដថា ការប្រើ ប្រាសគឺមានភាពសមរម្យ រក្សាបូរណភាពរបស់ប្រព័ន្ធ ហើយដើម្បីបញ្ជាក់ថាច្បាប់វិន័យរបស់សហព័ន្ធ និងរបស់រដ្ឋបានត្រូវអនុវត្តតាម។ ក្រសួងអប់រំ អាចកែឬដកចេញ នូវព័ត៏មានណាដែលគេយល់ឃើញថាពុំមានភាពសមរម្យ។

## ការប្រើប្រាសដែលមានភាពត្រឹមត្រូវ:

នៅពេលប្រើប្រាសប្រព័ន្ធបណ្តាញរបស់ក្រសួងអប់រំ ជាមួយឧបករណ៏របស់ក្រសួងអប់រំក្តី ឬជាមួយឧបករណ៏ផ្ទាល់ខ្លួនក្តី សិស្សត្រូវរក្សាខ្ជាប់នូវស្តង់ដា ខ្ពង់ខ្ពស់នៃសិលធម៏ហើយប្រើប្រាសប្រព័ន្ធនេះដោយសុវត្ថិភាពនិងមានទំនួលខុសត្រូវហើយសម្រាប់តែនៅក្នុងការសិក្សាតែប៉ុណ្ណុះ:

១. សិស្សដែលមានឈ្មោះអនុញ្ញាតឲ្យប្រើប្រាសអ៊ិនធើនែតត្រូវទទួលខុសត្រូវទៅលើការប្រើប្រាសដោយត្រឹមត្រូវគ្រប់ពេលវេលា។ សិស្សត្រូវរក្សាលេខ សំគាល់ខ្លួននិងលេខសំងាត់ឲ្យជិតហើយប្រើតែលេខសំគាល់ខ្លួនរបស់ខ្លួនឯងផ្ទាល់ប៉ុណ្ណុះ។

២. សិស្សត្រូវប្រើប្រាសប្រព័ន្ធរបស់ក្រសួងអប់រំដោយសុវត្ថិភាពនិងមានទំនួលខុសត្រូវហើយសម្រាប់តែនៅក្នុងការសិក្សាតែប៉ុណ្ណុះ។

៣. សិស្សមិនត្រូវចូលទៅ ដាក់តាំង ចុះផ្សាយ ឬបង្ហាញអ្វីៗដែលមិនល្អឬមិនសមរម្យ គឺអ្វីៗដែលជាការគំរាម អាសអាភាស ការរំខាន រូបភាពផ្លូវភេទ ឬអ្វីៗដែលចាត់ទុកថាជាការបីឌាយាយីឬការបង្អាប់បង្អួចដល់អ្នកដ៏ទៃយោងទៅតាមពូជសាសន៏ ជាតិពន្ធកំណើត ភេទ ចំណូលផ្ទាល់ខ្លួនផ្នែកផ្លូវភេទ អាយុ ពិការភាព សាសនា ឬជំនឿលើបក្សនយោបាយណាមួយ។

៤. លើកលែងតែបានបញ្ជាដោយបុគ្គលិកសាលា សិស្សមិនត្រូវបង្ហាញឬចែកផ្សាយនូវព័ត៏មានផ្ទាល់ខ្លួន(ឈ្មោះ អាស័យដ្ឋានលេខទូរស័ព្ទ លេខសន្តិច្ឆ័យ សង្គ្រោះ ឬព័ត៏មានសំគាល់ខ្លួនអ្វីផ្សេងទៀត) របស់ខ្លួនឯងឬរបស់អ្នកដ៏ទៃ នៅពេលប្រើអ៊ីមែល ឆាតរូម ឬប្រព័ន្ធទំនាក់ទំនងតាមអ៊ិនធើនែតផ្សេង ទៀត។ សិស្សត្រូវប្រយត្នក្នុងការបញ្ចេញព័ត៏មានទាំងនេះទៅឲ្យបុគ្គលដ៏ទៃដែលបានធ្វើទំនាក់ទំនងគ្នាតាមអ៊ិនធើនែត ដោយគ្មានការយល់ព្រមពីមាតា បិតាឬអ្នកអាណាព្យាបាល។

៥. សិស្សមិនត្រូវប្រើប្រព័ន្ធអ៊ិនធើនែតដើម្បីលើកទឹកចិត្តឲ្យប្រើប្រាស់គ្រឿងញៀន សុរា ឬថ្នាំជក់ ហើយមិនត្រូវផ្សព្វផ្សាយពីអំពើរខ្វះសីលធម៌និងសកម្មភាពអ្វីដែលច្បាប់ហាមឃាត់ឬហាមឃាត់ដោយបទបញ្ជានៃក្រុមប្រឹក្សាភិបាលអប់រំទេ។

៦. សិស្សមិនត្រូវប្រើប្រព័ន្ធអ៊ិនធើនែតដើម្បីចូលរួមក្នុងការធ្វើពាណិជ្ជកម្មឬសកម្មភាពជួញដូរយកចំណេញផ្សេងៗទៀត។

៧. សិស្សមិនត្រូវប្រើប្រព័ន្ធដើម្បីគំរាមកំហែង សំឡុតបំភ័យធ្វើការបីឌាឃាយី ឬលេងចំអកដល់សិស្សដ៏ទៃរៀតឡើយ។

៨. សិស្សមិនត្រូវដោយចេតនា ដោនឡូត ដាក់បញ្ចូល ឬបង្កើតវីរុសកុមព្យូទ័រ និង/ ឬព្យាយាមបំផ្លិចបំផ្លាញគ្រឿងសម្ភារៈ ឬឧករណ៏របស់ក្រសួងអប់រំ ឬកែផ្លាស់ប្តូរទិន្នន័យរបស់សិស្សដ៏ទៃទៀត ដែលរួមទាំងការប្រើវិធីក្លែងបន្លំចូលទៅកន្លែងហាមឃាត់ផងដែរ។ សិស្សត្រូវបានហាមឃាត់មិនឲ្យដាក់បញ្ចូលប្រូក្រាមទៅក្នុងកុំព្យូទ័រឬបណ្តាញក្រសួងអប់រំឡើយ។

៩. សិស្សមិនត្រូវព្យាយាមរារាំងសិស្សដ៏ទៃពីការប្រើប្រាស ដូចជាការផ្ញើនិងទទួលអ៊ីមែល ហើយមិនត្រូវព្យាយាមអានលប់ចោល ចម្លង ឬកែប្តូរអត្តសញ្ញាណកម្មរបស់អ្នកប្រើប្រាសដ៏ទៃទៀតឡើយ។

១០.សិស្សត្រូវធ្វើរបាយការណ៏ប្រាប់គ្រូបង្រៀនឬនាយកសាលា អំពីបញ្ហាសន្តិសុខអ្វីមួយឬការប្រើប្រាសប្រព័ន្ធដោយមិនត្រឹមត្រូវ។

**ច្បាប់រក្សាសិទ្ធិមិនឲ្យចម្លង**

១១.ព័ត៏មានអ្វីដែលគេរក្សាសិទ្ធិអាចតាំងបង្ហាញតាមអ៊ិនធើនែតបានលុះណាបើវាស្របទៅតាមច្បាប់រក្សាសិទ្ធិ។ ព័ត៏មានអ្វីដែលបានយកមកប្រើប្រាសនៅក្នុងការសិក្សាស្រាវជ្រាវត្រូវតែបានផ្តល់ក្រេឌិតត្រឹមត្រូវដល់ប្រភពនៃព័ត៏មានទាំងនោះ។

១២.សិស្សណាម្នាក់ដែលចាប់បានថាកំពុងតែផ្ញើបន្តនូវសំណុំបញ្ជីព័ត៏មានមិនស្របច្បាប់ ហើយគណនីរបស់អ្នកណាម្នាក់ដែលត្រូវរកឃើញថាមាននូវសំណុំបញ្ជីមិនស្របតាមច្បាប់អាចត្រូវដកហូតគណនីលែងឲ្យប្រើប្រាស។

**ការដាក់ពិន័យទៅលើការបំពានលើកិច្ចព្រមព្រៀង**

អភិបាលនៃប្រព័ន្ធបណ្តាញកុំព្យូទ័ររបស់ក្រសួងអប់រំឡុងប៊ីចរួម ជាមួយអភិបាលសាលានិងអ្នកតម្រួតឋានៈខ្ពស់គឺជាអ្នកសំរេចចិត្តថាអំពើរណាខ្លះដែលសន្មតថាមិនមែនជាអកប្បកិរិយាសមរម្យ។ ការបំពានលើចំណុចណាមួយនៃការព្រមព្រៀងនេះអាចបណ្តាលឲ្យឈប់អាចប្រើកុមព្យូទ័រនិងប្រព័ន្ធអ៊ិនធើនែត ឬទទួលពិន័យអប់រំព្រមទាំងអាចត្រូវទទួលទណ្ឌកម្មផងដែរ ដូចមានចែងក្នុងច្បាប់របស់រដ្ឋនិងសហព័ន្ធ និង/ ឬច្បាប់អប់រំ។

**កិច្ចព្រមព្រៀង:**

នៅក្នុងកិច្ចព្រមព្រៀងនេះ សិស្សហើយនិងមាតាបិតាឬអ្នកអាណាព្យាបាលត្រូវសុខចិត្តព្រមព្រៀងថានឹងមិនចាប់ឲ្យក្រសួងអប់រំឬបុគ្គលិករបស់ក្រសួងអប់រំឲ្យទទួលខុសត្រូវទៅលើការបរាជ័យនៃវិធានការណ៏បង្ការការពារប្រព័ន្ធប្រើប្រាសបច្ចេកទេស ការបំពានលើបំរាមថតចម្លងសម្ភារៈដែលម្ចាស់បានរក្សាសិទ្ធិ ហើយនិងកំហុសឬការធ្វេសប្រហែសរបស់អ្នកប្រើប្រាស(សិស្ស)។ ពួកគេក៏គប្បីសុខចិត្តសងថ្លៃសោហ៊ុយ ហើយមិនចាប់បុគ្គលិកឬក្រសួងអប់រំឲ្យទទួលខុសត្រូវទៅលើការខូចខាត ការបាត់បង់ ឬថ្លៃឈ្នួលអ្វីមួយដែលបានកើតឡើង រួមទាំងការបាត់បង់ទិន្នន័យ ឬការអាក់ខាននៃសេវាកម្មផងដែរ។

ខ្ញុំបានអាន យល់ច្បាស់ ហើយសុខចិត្តគោរពតាមលក្ខខ័ណ្ឌនៃការព្រមព្រៀងទៅលើការប្រើប្រាសអ៊ិនធើនែតឲ្យសមរម្យដោយសិស្សនៅក្នុងក្រសួងអប់រំឡុងប៊ីចនេះហើយ។ ខ្ញុំទទួលដឹងឮថាខ្ញុំនឹងទទួលខុសត្រូវទាំងស្រុងទៅលើការប្រើប្រាសកុំព្យូទ័រនិងប្រព័ន្ធបណ្តាញទំនាក់ទំនងរបស់ក្រសួងអប់រំ ហើយក៏ទទួលដឹងឮដែរថា ការប្រើប្រាសដោយខុសរបៀបលើសពីការអនុញ្ញាតរបស់ក្រសួងអប់រំអាចបណ្តាលឲ្យមានផលវិបាកឬខាតបង់ប្រាក់កាសផងដែរ។

ហត្ថលេខារបស់សិស្ស:_______________________________________________ សាលារៀន:____________________________

ហត្ថលេខាមាតាបិតាឬអ្នកអាណាព្យាបាល:_________________________________ ថ្ងៃខែ:_______________________________